



ចេញផ្សាយ ២៥ តុលា ២០២១

**ឯកឧត្តមរដ្ឋមន្ត្រី វេង សាខុន អមដំណើរដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល និងមន្ត្រីជំនាញបានអញ្ជើញមកពិនិត្យកសិដ្ឋានចិញ្ចឹមត្រី របស់លោក ផៃ ជាត និងសិប្បកម្មកែច្នៃត្រីងៀតរបស់បងស្រី ធឿន ស្រីនី ដែលមានទីតាំងស្ថិតនៅក្នុងភូមិថ្មី ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម**

នៅព្រឹកថ្ងៃសៅរ៍ ២រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ដើម្បីជាការលើកទឹកចិត្ត ជំរុញ និងគាំទ្រដល់វារីវប្បករក្នុងស្រុកជើងព្រៃឲ្យកាន់តែរីកចម្រើនបន្ថែមទៀតទាំងការងារបច្ចេកទេសចិញ្ចឹម ការបង្កាត់ពូជត្រី ការផលិតចំណី និងការកែច្នៃ ធ្វើយ៉ាងឲ្យបានសមស្របទៅតាមតម្រូវការទីផ្សារទាំងគុណភាព សុវត្ថិភាព និងតម្លៃ និងជាពិសេសស្របតាមបរិបទនៃស្ថានភាព





រីករាលដាលជំងឺឆ្លងកូវីដ-១៩ ឯកឧត្តមរដ្ឋមន្ត្រី វេង សាខុន អមដំណើរដោយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល និងមន្ត្រីជំនាញបានអញ្ជើញមកពិនិត្យកសិដ្ឋានចិញ្ចឹមត្រី របស់លោក ផៃ ផាត នៅភូមិបឹងជ្រោយ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ កសិករ ផៃ ផាត និងសមាជិកក្រុមគ្រួសារមួយចំនួនទៀត ចាប់ផ្តើមចិញ្ចឹមត្រីតាំងពីឆ្នាំ២០០៨ ប្រភេទត្រីដែលគាត់ចិញ្ចឹមរួមមានត្រីឆ្តោ និងត្រីប្រា លើផ្ទៃដី ៧០០០ម៉ែត្រក្រឡា ចែកចេញជា ៥ស្រះ (សរុប ៣០០០ ម៉ែត្រក្រឡា) មានសមត្ថភាពផលិតត្រីឆ្តោ និងត្រីប្រាបាន ២៥-៣០តោន/ឆ្នាំ ដោយប្រើចំណីផលិតខ្លួនឯង និងក្រុមហ៊ុន។ ម្ចាស់កសិដ្ឋានបានឲ្យដឹងថា







ដោយសារតម្រូវការទីផ្សារ
មានការកើនឡើងជាលំដាប់
កសិដ្ឋាន នឹងពង្រីកផ្ទៃដី
ចិញ្ចឹមបន្ថែមទៀត។
ចេញពីកសិដ្ឋានលោក ផៃ
ផាន ឯកឧត្តមរដ្ឋមន្ត្រី និង
សហការីបានបន្តដំណើរមក
កសិដ្ឋានចិញ្ចឹម និងសិប្បកម្ម
កែច្នៃត្រីងៀតរបស់បងស្រី
ធឿន ស្រីនី ដែលមានទីតាំង
ស្ថិតនៅក្នុងភូមិថ្មី ឃុំសូទិព្វ
ស្រុកជើងព្រៃ ខេត្តកំពង់ចា
ម។ បងស្រី ស្រីនី (០៩៩
៨៨៤៨៣៨) បានជម្រាបថា
៖ កសិដ្ឋាន បានដំណើរការ
មក ៧ឆ្នាំមកហើយ បច្ចុប្បន្ន
មានស្រះចិញ្ចឹមត្រីប្រាធំៗ
ចំនួន ៨ស្រះ សរុបដាក់កូន
ត្រីចិញ្ចឹម ១លានកូន។
ដោយអនុវត្តតាមគោល
ការណ៍បច្ចេកទេសចិញ្ចឹមត្រី
ដូចជាការផ្តល់ចំណី ការ
សំអាតស្រះ ការគ្រប់គ្រង
ប្រើប្រាស់ និងសម្អាតទឹក។
ល។ រួមផ្សំជាមួយពូជល្អ





